**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូតវែរ ឯ.ក

## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានផ្នែកប្រចាំក្រុមហ៊ុន

នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២៣ វេលាម៉ោង ០៩ និង ០០ នាទី នៅក្នុងក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូតវែរ ឯ.ក មានធ្វើកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករ និយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះការបញ្ជាទិញ ដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការខ្លះៗ ។ ហេតុនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចំនួន ៣០២ នាក់ (ស្រីចំនួន ២១៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៤៦២ នាក់ (ស្រី ៣១៣នាក់) ។

រយៈពេលមួយខែ ចាប់គិតពី ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ។

ហើយកំឡុងពេលព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតបានឯកភាពទទួលផ្តល់ជូនរបស់រោងចក្រ នៅប្រាក់ឈ្នួលក្នុងមួយខែពេញចំនួន ៣០ ដុល្លារ(សាបសិប ) ដុល្លារអាមេរិចនៃប្រាក់ឈ្នួលប្រចាំ ថ្ងៃ ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ នឹងបើកជូនបងប្អូនកម្មករនិយោជិត មុនមួយថ្ងៃនៃថ្ងៃឈប់សំរាក នឹងបើកជូននៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣ ចំនួន ៣០ (សាបសិប) ដុល្លារ អាមេរិច ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១១ និង ០០ នាទី នាព្រឹកថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ នឹងស្និទស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់គ្នា ទៅវិញទៅមក ។ ដើម្បីបញ្ជាក់ក្នុងកិច្ចព្រមព្រៀងនេះ គ្រប់ភាគីទាំងអស់បានចុះហត្ថលេខា ឬផ្តិតមេដៃទុកជា ភស្តុតាងស្រាប់ ។

ថ្ងៃព្រហស្បត៍ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ស្ពឺថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២៣

**ស្នាមមេដៃប្រតិភូបុគលិក**

ឃុន ប៊ុនណា

តាំង គង់ម៉េង

កួយ ម៉េត

សាំង ស្រីតួច

វ៉ាង ស្រីនិច

ស៊ឹម អែម

**ហត្ថលេខា និងត្រា**

**តំណាងក្រុមហ៊ុន**

HENGSIM FOOTWEAR

KINGDOM OF CAMBODIA

Wu CongGang